ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2012, 16:53
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១១)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(11)

**នៅចំពោះមុខ៖**
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Motoo Noguchi
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Chandra Nihal Jayasinghe
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងស្តីពី អញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន ៨៩ នៃ វិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ(Ne Bis in Idem)* និងការលើកលែងទោស និងការអនុគ្រោះទោស)

**<u>សហមេធាវីការពារក្តីជនជាប់ចោទ៖</u>**

អាង ឧត្តម

Michael G. KARNAVAS

**<u>ជនជាប់ចោទ៖</u>**

អៀង សារី

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>សហព្រះរាជអាជ្ញា៖</u>**

ជា លាង

Andrew CAYLEY

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)៖

**បានទទួល** បណ្តឹងសាទុក្ខដែលបានដាក់ដោយសហមេធាវីការពារក្តីជនជាប់ចោទ អៀង សារី (“បណ្តឹងសាទុក្ខ”)[១] ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានច្រានចោលអញ្ញត្រកម្មរបស់ជនជាប់ចោទ ចំពោះយុត្តាធិការរបស់ អ.វ.ត.ក ដោយផ្អែកលើគោលការណ៍ *អាជ្ញាអស់ជំនុំ* (*res judicata*) តាមច្បាប់កម្ពុជា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (*ne bis in idem*) តាមមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសដែលព្រះមហាក្សត្រសម្តេចឪ នរោត្តម សីហនុ បានប្រទានដល់ជនជាប់ចោទ កាលពីឆ្នាំ ១៩៩៦[២]។

**ដោយពិចារណាទៅលើ** អត្ថបទនៃវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ដែលបានផ្តល់សិទ្ធិប្តឹងសាទុក្ខដល់ភាគីដើម្បីជំទាស់ទៅនឹងសេចក្តីសម្រេចដែល “មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី”។

**ដោយពិចារណាទៅលើ**ទឡ្ហីករណ៍ដែលបានដាក់ដោយមេធាវីការពារក្តីដែលអះអាងថា បណ្តឹងសាទុក្ខអាចទទួលយកបាន ដោយសារថា សហព្រះរាជអាជ្ញាក៏ប្រហែលជាបានប្រើប្រាស់សិទ្ធិដាក់បណ្តឹងសាទុក្ខភ្លាមៗ តាមវិធាន ១០៤(៤)(ក) ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ ហើយថា គោលការណ៍សមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តីតម្រូវថា មេធាវីការពារក្តីក៏មានសិទ្ធិប្តឹងសាទុក្ខដែរ[៣]។

**ដោយពិចារណាទៅលើ**យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះដែលបញ្ជាក់ថា វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យប្តឹងសាទុក្ខដែលក្នុងករណីជំទាស់ទៅនឹងសេចក្តីសម្រេច ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ[៤]

---

[១] បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី អញ្ញត្រកម្មរបស់លោកអៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne Bis in Idem)* និងការលើកលែងទោស និងការអនុគ្រោះទោស), ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារលេខ E51/15/1/1។

[២] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne Bis in Idem)* និងការលើកលែងទោស និងការអនុគ្រោះទោស), ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E51/15 (“សេចក្តីសម្រេចដែលត្រូវបានជំទាស់”)។

[៣] បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧-៩។

[៤] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ចុះ

ដោយពុំសំដៅឲ្យមានការដាក់បណ្ដឹងសាទុក្ខប្រឆាំងរាល់សេចក្ដីសម្រេចទាំងអស់ ពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។

**ដោយបានឃើញ** យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះដែលបញ្ជាក់ថា វិធាន ១០៤ នៃវិធានផ្ទៃក្នុងស្របទៅនឹងគោលការណ៍សមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្ដី ដោយសារថា ជនជាប់ចោទនឹងមានឱកាសប្ដឹងសាទុក្ខចំពោះសេចក្ដីសន្និដ្ឋាននៅក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់ ជាផ្នែកមួយនៃបណ្ដឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រម[៥]។ និង

**ដោយបានឃើញ** ភាគីពុំមានសិទ្ធិជាទូទៅក្នុងការប្ដឹងសាទុក្ខបន្ទាន់បង្គំ[៦]ទេ។

**យោងតាមសំអាងហេតុខាងលើ** អង្គជំនុំជម្រះតុលាការកំពូល (ចៅក្រម KLONOWIECKA-MILART និងចៅក្រម JAYASINGHE ជំទាស់)៖

**សម្រេច** បដិសេធបណ្ដឹងសាទុក្ខថាមិនអាចទទួលយកបានទេ។

មតិជំទាស់ដាច់ដោយឡែករបស់ចៅក្រម KLONOWIECKA-MILART និងចៅក្រម JAYASINGHE នឹងចេញតាមក្រោយក្នុងពេលឆាប់ៗ។

ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារលេខ E95/8/1/4 ("សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខស្ដីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ"), កថាខណ្ឌ ៨។

[៥] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខស្ដីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ, កថាខណ្ឌ ៩។

[៦] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Norman*, សំណុំរឿងលេខ SCSL-2003-08-PT, "សេចក្ដីសម្រេចលើពាក្យសុំផ្អាកកិច្ចដំណើរការនីតិវិធី និងការបដិសេធសិទ្ធិប្ដឹងឧទ្ធរណ៍, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣, កថាខណ្ឌ ១៨-២៥ (សិទ្ធិតាមមាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុវត្តចំពោះការផ្ដន្ទាទោស និងការកំណត់ទោសស្ថាពរ)។

**រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**